**សម្រេច**

**មាត្រា ១ :** អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ លើមុខសញ្ញាជួសជុលស្នាក់ការគណៈកម្មាធិការអន្តរជាតិទន្លេមេគង្គនៅរាជធានីភ្នំពេញ ដែលមានទឹកប្រាក់ប្រមាណ 600.000 USD (ប្រាំមួយរយពាន់ ដុល្លារអាមេរិក) ។ ចំនួនទឹកប្រាក់ពិតប្រាកដ នឹងកំណត់ក្រោយពីធ្វើបែបបទលទ្ធកម្មសាធារណៈរួច ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ២៤ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មការជាតិអេស្កាប់**

* * *

**រាជរដ្ឋាភិបាល**

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយកយករដ្ឋមន្ត្រីទី ១ និងទី ២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណូមពរការងារចាំបាច់

**សំរេច**

**មាត្រា ១ :** បង្កើតគណៈកម្មការជាតិសេដ្ឋកិច្ចនិងសង្គមកិច្ច សំរាប់តំបន់អាស៊ីប៉ាស៊ីហ្វិក (Economic and Social Commission for Asia and Pacific) ដែលហៅកាត់ថា « គណៈកម្មការជាតិ អេស្កាប់ (E S C A P) ហើយមានសមាសភាពដូចតទៅ ÷

| | |
|---|---|
| ១-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | ជាប្រធាន |
| ២-ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងផែនការ | ជាអនុប្រធាន |
| ៣-ឯកឧត្តម អគ្គលេខាធិការ គជនា/កអក. | ជាសមាជិក |
| ៤-តំណាង អេស្កាប់ នៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងបាងកក ប្រទេសថៃឡង់ដ៍ | ជាសមាជិក |
| ៥-តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| ៦-តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៧-តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| ៨-តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល | ជាសមាជិក |
| ៩-តំណាងក្រសួងបរិស្ថាន | ជាសមាជិក |
| ១០-តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ១១-តំណាងក្រសួងអប់រំ យុវជននិងកីឡា | ជាសមាជិក |

១២– តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

១៣– តំណាងក្រសួងកិច្ចការនារី ជាសមាជិក

១៤– តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាសមាជិក

១៥– តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ជាសមាជិក

១៦– អនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គ ជាសមាជិក

១៧– តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិក

១៨– តំណាងក្រសួងសុខាភិបាល ជាសមាជិក

**មាត្រា២ :** គណៈកម្មការជាតិ អេស្កាប់ មានភារកិច្ចនិងតួនាទី :

– ជាគណៈបញ្ជាការឯកភាពមួយដោយសហការយ៉ាងជិតស្និទ្ធ និងសំរបសំរួល ជាមួយបណ្តាក្រសួងស្ថាប័នដែលពាក់ព័ន្ធ ដើម្បីប្រមូលផ្តុំបណ្តាសំណូមពរចាំបាច់បំរើអោយការស្តារឡើងវិញ ការកសាងនិងអភិវឌ្ឍន៍សេដ្ឋកិច្ច–សង្គមកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ។

– តាមដានការរីកចំរើននៃសកម្មភាពរបស់អង្គការនេះ ។

– រាយការណ៍ និងសុំយោបល់ពីរាជរដ្ឋាភិបាលអំពីបញ្ហាសំខាន់ៗដែលហួសពីសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា ៣ :** គណៈកម្មការជាតិ អេស្កាប់ចាំបាច់ត្រូវរៀបចំថវិកាដោយឡែកមួយ តែជាឧបសម្ព័ន្ធថវិការបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដើម្បីកិច្ចដំណើរការអោយមានប្រសិទ្ធភាពរបស់គណៈកម្មការជាតិអេស្កាប់ ។

**មាត្រា ៤ :** គណៈកម្មការជាតិ អេស្កាប់ ត្រូវមានត្រាដោយឡែករបស់ខ្លួន ។

**មាត្រា ៥ :** សមាជិកគណៈកម្មការជាតិ អេស្កាប់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធានក្នុងករណីអវត្តមានរបស់ប្រធាន ។

**មាត្រា ៦ :** គណៈកម្មការជាតិ អេស្កាប់ ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនសំរាប់ដំណើរការជាក់ស្តែង ។

**មាត្រា ៧ :** គណៈកម្មការជាតិ អេស្កាប់ មានការិយាល័យប្រតិបត្តិមួយនៅទីស្តីការក្រសួងសាធារណការនិងដឹកជញ្ជូន ។

មាត្រា ៨ : ការិយាល័យប្រតិបត្តិនេះ មានសមាសភាពដូចខាងក្រោម ៖

១–តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន ជាប្រធាន

២–តំណាងក្រសួងផែនការ ជាអនុប្រធាន

៣–តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៤–តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

ការិយាល័យប្រតិបត្តិនេះមានបុគ្គលិកបំពេញការអចិន្ត្រៃយ៍មួយចំនួន តាមការរៀបចំរបស់គណៈកម្មការជាតិ អេស្កាប់ ។

មាត្រា ៩ : ការិយាល័យប្រតិបត្តិនេះ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម ៖

–ជាយន្តការជំនួយការអចិន្ត្រៃយ៍របស់គណៈកម្មការជាតិ អេស្កាប់ ។

–រៀបចំកម្មវិធី និងខ្លឹមសារសំរាប់អង្គប្រជុំនៃគណៈកម្មការជាតិ អេស្កាប់ ។

–ជំរុញនិងតាមដានការអនុវត្តន៍សេចក្តីសំរេចរបស់អង្គការ អេស្កាប់ ។

–សិក្សាស្រាវជ្រាវនិងលើកឡើងពីទិសដៅ នានា សំរាប់អង្គប្រជុំនៃអង្គការអេស្កាប់ជូនគណៈកម្មការជាតិ អេស្កាប់ ។

–ប្រមូលផ្តុំចម្លង និងចែកចាយឯកសារ ដល់គ្រប់ក្រសួង ស្ថាប័នលើការងារពាក់ព័ន្ធ ។

–ធ្វើរបាយការណ៍តាមកាលកំណត់ជូនគណៈកម្មការជាតិ អេស្កាប់ ។

មាត្រា ១០ : អនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៥ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១១ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងផែនការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានគណៈកម្មាធិការជាតិទន្លេ

មេតង្គ ឯកអគ្គរាជទូតកម្ពុជាប្រចាំរាជាណាចក្រថៃឡង់ដ៍ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ៨ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្ថលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ២៥ អនក្រ.បក**

**ស្ដីពីការបង្កើតគណៈកម្មាធិការ**

**សំរាប់គោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ស្ដីពី ការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពី ការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា